**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៧-៣៣៥ ប្រ.ក

**ប្រកាស**
**ស្តីពី**
**សវនកម្ម ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

---

**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា ជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពី ការកែសម្រួល ប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ១២ និងប្រការ ១៣ នៃប្រកាសស្តីពី រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧

**សម្រេច**
**ជំពូកទី ១**
**បទប្បញ្ញត្តិទូទៅ**

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ដើម្បីទទួលស្គាល់ក្រុមហ៊ុនសវនកម្មដែលធ្វើសវនកម្មគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងកំណត់កាតព្វកិច្ចរបស់ក្រុមហ៊ុនសវនកម្មដែលត្រូវបានទទួលស្គាល់ តទៅនេះហៅថា "ក្រុមហ៊ុន" និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្ម តទៅនេះហៅថា "សវនដ្ឋាន"។



1

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ២.-**

ប្រកាសនេះ មានគោលដៅ ដើម្បី៖

- ធានានូវភាពត្រឹមត្រូវនិងសុចរិតនៃព័ត៌មាននិងទិន្នន័យហិរញ្ញវត្ថុ ដែលសវនដ្ឋានផ្តល់ជូនធនាគារជាតិនៃកម្ពុជា និងភាគីពាក់ព័ន្ធ
- លើកកម្ពស់ប្រសិទ្ធភាពនៃការត្រួតពិនិត្យ ដោយអនុលោមតាមបទដ្ឋាននិងឧត្តមានុវត្តជាតិនិងអន្តរជាតិ និង
- ពង្រឹងគុណភាពការងារសវនកម្មរបស់ក្រុមហ៊ុន។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុន ដែលទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា និងសវនដ្ឋាន ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤.-**

សម្រាប់គោលបំណងនៃប្រកាសនេះ៖ពាក្យបច្ចេកទេសមួយចំនួនត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

**សមត្ថភាពវិជ្ជាជីវៈ** (Competence) សំដៅដល់សមត្ថភាពរបស់សវនករ ក្នុងការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងអនុវត្តការងារសវនកម្មសំខាន់ៗដូចជា ការកំណត់និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត ការរៀបចំ និងអនុវត្តយន្តការសមស្របដើម្បីគ្រប់គ្រងហានិភ័យទាំងនោះ។

**ភាពមិនលំអៀង** (Objectivity) សំដៅដល់ការវិនិច្ឆ័យរបស់សវនករ ដោយមិនមានទំនាស់ផលប្រយោជន៍។ សវនករត្រូវមានឯករាជ្យភាពទាំងស្រុងក្នុងការបំពេញមុខងារ-ភារកិច្ចសវនកម្ម។

**ឯករាជ្យភាព** (Independence) សំដៅដល់ការមិនរារាំងពីស្ថានភាព និងពីទំនាក់ទំនងទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់ការវិនិច្ឆ័យដោយឯករាជ្យ និងមិនលំអៀងរបស់សវនករ។ ឯករាជ្យភាពនេះត្រូវមានគ្រប់ពេលក្នុងការទំនាក់ទំនងជាមួយសវនដ្ឋាន និងជាមួយស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនឹងសវនដ្ឋាន។

**ក្រមសីលធម៌** (Code of Ethics) សំដៅដល់ក្រមសីលធម៌វិជ្ជាជីវៈ ដែលប្រកាសឲ្យប្រើដោយស្ថាប័នមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ដៃគូសវនកម្ម** (Engagement Partner) សំដៅដល់រូបវន្តបុគ្គលក្នុងក្រុមហ៊ុនសវនកម្ម ដែលជាអ្នកទទួលខុសត្រូវចំពោះរាល់កិច្ចការពាក់ព័ន្ធការធ្វើសវនកម្ម និងចំពោះការចេញផ្សាយរបាយការណ៍សវនកម្មក្នុងនាមក្រុមហ៊ុន។

**សមាជិកគ្រួសារផ្ទាល់** (Immediate Family Member) សំដៅដល់ទំនាក់ទំនងជា ប្ដី ប្រពន្ធ កូន ឪពុកម្ដាយ បងប្អូនបង្កើត ឬបុគ្គលនៅក្រោមអាណាព្យាបាលរបស់បុគ្គលណាម្នាក់។

## ជំពូកទី ២
## លក្ខខណ្ឌនៃការទទួលស្គាល់

**ប្រការ ៥.-**

ក្រុមហ៊ុន ដែលមានបំណងធ្វើសវនកម្មលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ត្រូវមានគុណវុឌ្ឍិ ដូចខាងក្រោម៖

១. បានចុះបញ្ជីពាណិជ្ជកម្ម

២. ជាសមាជិកវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (វ.គ.ស.ក.)

៣. មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៤. មានដៃគូសវនកម្ម និងសវនករ ជាសមាជិកសកម្ម នៅ វ.គ.ស.ក. យ៉ាងតិច ០២ (ពីរ) រូប ដែលមានគុណវុឌ្ឍិដូចមានចែងក្នុងប្រការ ៧

៥. មានសកម្មភាពធុរកិច្ចសវនកម្ម និងមានកេរ្តិ៍ឈ្មោះល្អ យ៉ាងតិច ០៣ (បី) ឆ្នាំ គិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំ

៦. មានការពិនិត្យគុណភាពការងារសវនកម្មជាប្រចាំ និង

៧. បំពេញលក្ខខណ្ឌផ្សេងទៀត ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

**ប្រការ ៦.-**

ក្រុមហ៊ុន ដែលដាក់ពាក្យស្នើសុំ ត្រូវភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម៖

១. សារតារក្រុមហ៊ុន

២. វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

៣. វិញ្ញាបនបត្រចុះបញ្ជីជាសមាជិករបស់ វ.គ.ស.ក.

៤. អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីក្រុមប្រឹក្សាជាតិគណនេយ្យនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៥. បញ្ជីឈ្មោះដៃគូសវនកម្ម និងសវនករដែលជាសមាជិកសកម្មនៅ វ.គ.ស.ក. ដោយភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រចុះឈ្មោះជាសមាជិកសកម្ម លិខិតថ្កោលទោស និងប្រវត្តិរូបដែលមានបញ្ជាក់អំពី គុណវុឌ្ឍិ បទពិសោធន៍ និងរយៈពេលបំពេញការងារ

៦. នីតិវិធីនៃការធ្វើសវនកម្ម

៧. ព័ត៌មានស្ដីពីការផ្ដល់សេវាសវនកម្ម ក្នុងអំឡុងពេល ០៣ (បី) ឆ្នាំ ចុងក្រោយ

៨. របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសាមីដែលត្រូវបានធ្វើសវនកម្ម ក្នុងរយៈពេល ០៣ (បី) ឆ្នាំ ចុងក្រោយ និង

៩. ឯកសារផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។



2

**ប្រការ ៧.-**

ដៃគូសវនកម្ម និងសវនករ ដែលជាសមាជិកសកម្មរបស់ វ.គ.ស.ក. ត្រូវមានគុណវុឌ្ឍិបន្ថែម ដូចខាងក្រោម៖

១. ជាបុគ្គលដែលមានលក្ខណៈសម្បត្តិស្របតាមលក្ខខណ្ឌនៃនិច្ច័យត្រឹមត្រូវនិងសមស្រប

២. បំពេញលក្ខខណ្ឌនៃភាពមិនលំអៀងនិងឯករាជ្យភាព ស្របតាមក្រមសីលធម៌ដែលប្រកាសឲ្យប្រើដោយស្ថាប័នមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៣. មានបទពិសោធន៍យ៉ាងតិច ០៣ (បី) ឆ្នាំ ក្នុងការងារសវនកម្មនៅក្នុងវិស័យធនាគារ និង

៤. មានចំណេះដឹង និងសមត្ថភាពគ្រប់គ្រាន់ពាក់ព័ន្ធនឹងក្របខ័ណ្ឌបទប្បញ្ញត្តិ និងការគ្រប់គ្រងហានិភ័យក្នុងវិស័យធនាគារ។

**ប្រការ ៨.-**

ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការទទួលស្គាល់ ឬមិនទទួលស្គាល់ក្រុមហ៊ុន ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់។

## ជំពូកទី ៣
## ភារកិច្ចរបស់ក្រុមហ៊ុន និងសវនដ្ឋាន

**ប្រការ ៩.-**

ក្រុមហ៊ុន ត្រូវមានភារកិច្ច ដូចខាងក្រោម៖

១. ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់សវនដ្ឋាន

២. វាយតម្លៃលើរបាយការណ៍ផ្សេងទៀតរបស់សវនដ្ឋាន ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា

៣. រាយការណ៍ជាបន្ទាន់មកធនាគារជាតិនៃកម្ពុជាអំពីភាពមិនប្រក្រតី ដែលទាក់ទងទៅនឹងអសាធនភាព ឬហានិភ័យធ្ងន់ធ្ងរដែលអាចនាំឲ្យសវនដ្ឋានឈានទៅរកអសាធនភាព ការមិនអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងសកម្មភាពបច្ចុប្បន្ន ឬផែនការអនាគតដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់កិច្ចការពារផលប្រយោជន៍របស់អ្នកដាក់ប្រាក់បញ្ញើ និងភាគីពាក់ព័ន្ធ

៤. មិនត្រូវផ្ដល់ដល់សវនដ្ឋាននូវ ព័ត៌មាន និងឯកសារ ដូចមានចែងក្នុងចំណុច ៣ ខាងលើ

៥. រាយការណ៍មកធនាគារជាតិនៃកម្ពុជា អំពីការផ្លាស់ប្ដូរបុគ្គលិកដែលពាក់ព័ន្ធនឹងការងារសវនកម្មរបស់សវនដ្ឋានដោយមិនបានគ្រោងទុក ក្នុងអំឡុងពេលធ្វើសវនកម្ម

៦. ផ្ដល់ឯកសារលទ្ធផលនៃការពិនិត្យគុណភាពការងារសវនកម្ម ជូនមកធនាគារជាតិនៃកម្ពុជាតាមការតម្រូវ

៧. ជូនដំណឹងមកធនាគារជាតិនៃកម្ពុជានូវព័ត៌មាន ដែលបានធ្វើបច្ចុប្បន្នកម្មទាក់ទងទៅនឹងការផ្លាស់ប្ដូរសំខាន់ៗ រួមមាន ការផ្លាស់ប្ដូរដៃគូសវនកម្ម សមាជិកសកម្ម និងគណៈគ្រប់គ្រងជាន់ខ្ពស់ និង

៨. ផ្ដល់ឯកសារ ឬព័ត៌មានផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុន ត្រូវបំពេញពាក្យស្នើសុំការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ស្របតាមឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ១០.-**

ក្នុងករណីមានការធ្វើសវនកម្មពិសេស ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍សវនកម្មពិសេសនេះ ជូនធនាគារជាតិនៃកម្ពុជា និងក្រុមប្រឹក្សាភិបាលរបស់សវនដ្ឋាន។

បើគ្មានការកំណត់ផ្សេងពីធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុនត្រូវផ្តល់ការធានាសមស្រប (Reasonable Assurance) លើរបាយការណ៍សវនកម្មពិសេស និងជូនដំណឹងទៅសវនដ្ឋានជាលាយលក្ខណ៍អក្សរ។

**ប្រការ ១១.-**

ក្នុងគោលបំណងពង្រឹងគុណភាពសវនកម្ម និងតាមដានពីភាពរឹងមាំនៃប្រតិបត្តិការនិងការអនុវត្តតាមបទប្បញ្ញត្តិរបស់សវនដ្ឋាន ធនាគារជាតិនៃកម្ពុជាអាចរៀបចំកិច្ចប្រជុំរួមជាមួយសវនដ្ឋាន និងក្រុមហ៊ុន ដើម្បីពិភាក្សាលើរបាយការណ៍សវនកម្ម ការរកឃើញពីភាពមិនប្រក្រតី និងបញ្ហាផ្សេងទៀត។ ក្រៅពីកិច្ចប្រជុំនេះ កិច្ចប្រជុំរវាងធនាគារជាតិនៃកម្ពុជា ជាមួយក្រុមហ៊ុន អាចធ្វើឡើងតាមការចាំបាច់។

**ប្រការ ១២.-**

ក្រុមហ៊ុន ត្រូវគោរពតាមបទប្បញ្ញត្តិ ដូចខាងក្រោម៖

១. ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិសម្រាប់កម្ពុជា ដែលបានអនុម័តឲ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា
២. ស្តង់ដារសវនកម្មដែលបានអនុម័តឲ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា
៣. ក្រមសីលធម៌ និង
៤. ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ។

**ប្រការ ១៣.-**

ក្រុមហ៊ុនដែលទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា មិនត្រូវធ្វើសវនកម្មចំពោះសវនដ្ឋាន ប្រសិនបើក្រុមហ៊ុន៖

១. មានទំនាក់ទំនងសំខាន់ផ្នែកហិរញ្ញវត្ថុ និង/ឬ សេដ្ឋកិច្ច ដោយផ្ទាល់និងដោយប្រយោលជាមួយសវនដ្ឋាន
២. មានសមាជិកគ្រួសារផ្ទាល់ជា ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង ប្រធានសវនកម្មផ្ទៃក្នុង ប្រធានមុខងារប្រតិបត្តិតាម ប្រធានហិរញ្ញវត្ថុ និងបុគ្គលិកជាន់ខ្ពស់ពាក់ព័ន្ធផ្សេងទៀតរបស់សវនដ្ឋាន ឬ
៣. ទទួលអត្ថប្រយោជន៍ផ្ទាល់ ឬប្រយោលពីសវនដ្ឋាន និង/ឬ មានទំនាក់ទំនងផ្សេងទៀតដែលធនាគារជាតិនៃកម្ពុជាយល់ថា អាចបង្កឲ្យមានទំនាស់ផលប្រយោជន៍។

**ប្រការ ១៤.-**

ក្រុមហ៊ុន មិនត្រូវផ្តល់ដល់សវនដ្ឋាននូវសេវា ដូចខាងក្រោម៖

១. ការចុះកិច្ចបញ្ជិកា ឬសេវាផ្សេងទៀតទាក់ទងនឹងការកត់ត្រាគណនេយ្យ ឬរបាយការណ៍ហិរញ្ញវត្ថុ
២. ការបង្កើតនិងការដាក់ឲ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យាផ្នែកហិរញ្ញវត្ថុ

៣. សេវាសវនកម្មផ្ទៃក្នុង

៤. សេវាប្រឹក្សាផ្នែកពន្ធ និង

៥. សេវាផ្សេងៗដែលធនាគារជាតិនៃកម្ពុជាយល់ថា អាចបង្កឲ្យមានទំនាស់ផលប្រយោជន៍។

ក្នុងករណី ក្រុមហ៊ុនបានផ្ដល់សេវាណាមួយដូចរៀបរាប់ខាងលើដល់សវនដ្ឋាន ក្រុមហ៊ុនមិនត្រូវចុះកិច្ចសន្យាសវនកម្មជាមួយសវនដ្ឋាននោះឡើយ លើកលែងតែការផ្ដល់សេវាខាងលើត្រូវបានបញ្ចប់ទៅក្នុងរយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ សម្រាប់ចំណុច ១ និង ០១ (មួយ) ឆ្នាំ សម្រាប់ចំណុចផ្សេងទៀតនៃប្រការនេះ។

**ប្រការ ១៥.-**

ក្រុមហ៊ុន មិនត្រូវបានអនុញ្ញាតឲ្យធ្វើសវនកម្មជាបន្តបន្ទាប់លើសវនដ្ឋានតែមួយ លើសពីរយៈពេល ០៣ (បី) ឆ្នាំឡើយ។ ប៉ុន្តែសវនដ្ឋានទាំងឡាយណាដែលជាសាខា ឬជាបុត្តសម្ព័ន្ធរបស់ធនាគារបរទេសអាចជ្រើសរើសក្រុមហ៊ុនដូចទីស្នាក់ការកណ្ដាលរបស់ខ្លួនបាន ដោយគ្រាន់តែផ្លាស់ប្ដូរដៃគូសវនកម្មរៀងរាល់ ០៣ (បី) ឆ្នាំម្ដង។ ក្រុមហ៊ុន ដែលត្រូវបានប្ដូរចេញពីការធ្វើសវនកម្មនៅសវនដ្ឋានណាមួយ អាចត្រឡប់ទៅបំពេញសវនកម្មលើសវនដ្ឋានដដែលនោះវិញ បន្ទាប់ពីរយៈពេល ០២ (ពីរ) ឆ្នាំ ក្រោយបញ្ចប់ការបំពេញសវនកម្មលើកចុងក្រោយ។

**ប្រការ ១៦.-**

១. សវនដ្ឋាន ត្រូវមានកាតព្វកិច្ច ដូចខាងក្រោម៖

ក. រងការធ្វើសវនកម្មប្រចាំឆ្នាំ ដោយក្រុមហ៊ុន

ខ. ជ្រើសរើសក្រុមហ៊ុន និងស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ដោយភ្ជាប់មកជាមួយនូវឈ្មោះដៃគូសវនកម្មឲ្យបានមុនថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំប្រតិទិននីមួយៗ

គ. ផ្ដល់កិច្ចសន្យាសវនកម្មជូនធនាគារជាតិនៃកម្ពុជាឲ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនពេលចាប់ផ្ដើមធ្វើសវនកម្ម

ឃ. ផ្ដល់ឲ្យក្រុមហ៊ុននូវទិន្នន័យនិងព័ត៌មានទាំងអស់របស់សវនដ្ឋានទៅតាមវិសាលភាពនៃការធ្វើសវនកម្មនិងកាតព្វកិច្ចផ្នែកបទប្បញ្ញត្តិ ព្រមទាំងការណែនាំទាក់ទងនឹងការធ្វើសវនកម្មពីធនាគារជាតិនៃកម្ពុជា។ សវនដ្ឋានមិនត្រូវផ្ដល់របាយការណ៍ត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារជាតិនៃកម្ពុជាដល់ក្រុមហ៊ុន លើកលែងតែមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា

ង. អនុញ្ញាតឲ្យក្រុមហ៊ុនសាកសួរព័ត៌មានពី ក្រុមប្រឹក្សាភិបាល គណៈកម្មការ សវនករផ្ទៃក្នុង បុគ្គលិកពាក់ព័ន្ធតាមការចាំបាច់ និងអាចទទួលព័ត៌មានសំខាន់ៗផ្សេងទៀត ដើម្បីបំពេញការងាររបស់ខ្លួន ស្របតាមប្រកាសនេះ

ច. ធានាថាគណៈកម្មការសវនកម្មរបស់ខ្លួន ត្រូវពិនិត្យឡើងវិញលើកិច្ចសន្យាសវនកម្មរៀងរាល់ឆ្នាំ រួមទាំងការវាយតម្លៃពីឯករាជ្យភាពរបស់ក្រុមហ៊ុន

ឆ. ធានាថាប្រធានសវនកម្មផ្ទៃក្នុងរបស់ខ្លួន ត្រូវចូលរួមកិច្ចប្រជុំរវាង ធនាគារជាតិនៃកម្ពុជា សវនដ្ឋាន និងក្រុមហ៊ុន លើកលែងតែមានការកំណត់ផ្សេងទៀតពីធនាគារជាតិនៃកម្ពុជា និង

ជ. ផ្ដល់ជូនក្រុមប្រឹក្សាភិបាលនិងគណៈកម្មការសវនកម្មរបស់សវនដ្ឋាន និងធនាគារជាតិនៃកម្ពុជានូវរបាយការណ៍សវនកម្ម ព្រមទាំងឯកសារពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

២. ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជា អាចស្នើសវនដ្ឋានឲ្យតែងតាំងក្រុមហ៊ុន ដែលអាចជាក្រុមហ៊ុនកំពុងធ្វើសវនកម្ម ឬជាក្រុមហ៊ុនផ្សេងទៀត ឲ្យធ្វើសវនកម្មពិសេសលើផ្នែកណាមួយនៃប្រតិបត្តិការ របាយការណ៍តម្រូវដោយបទប្បញ្ញត្តិ របាយការណ៍ប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬស្ថានភាពហិរញ្ញវត្ថុរបស់សវនដ្ឋាន ជាដើម។

៣. ការចំណាយលើរាល់ការធ្វើសវនកម្មនិងចំណាយពាក់ព័ន្ធផ្សេងទៀត ជាបន្ទុករបស់សវនដ្ឋាន។

## ជំពូកទី ៤
## កម្រៃ និងសោហ៊ុយ

**ប្រការ ១៧.-**

ក្រុមហ៊ុនសវនកម្មដែលកំពុងដាក់ពាក្យស្នើសុំការទទួលស្គាល់ ត្រូវបង់សោហ៊ុយសាកសួរព័ត៌មាន និងសោហ៊ុយសិក្សាសំណុំលិខិត នៅពេលដាក់ពាក្យស្នើសុំ ដូចខាងក្រោម៖

១. សោហ៊ុយសាកសួរព័ត៌មាន : ៥០០.០០០ រៀល (ប្រាំរយពាន់រៀល)
២. សោហ៊ុយសិក្សាសំណុំលិខិត : ៤.០០០.០០០ រៀល (បួនលានរៀល)

ក្រុមហ៊ុន ដែលត្រូវបានទទួលស្គាល់ ត្រូវបង់សោហ៊ុយ ប្រចាំឆ្នាំចំនួន ២០.០០០.០០០ រៀល (ម្ភៃលានរៀល) ឲ្យបានមុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំ។

ក្រុមហ៊ុន ដែលត្រូវបានទទួលស្គាល់ក្នុងឆ្នាំ ត្រូវបង់សោហ៊ុយ ដូចខាងក្រោម៖

- ក្នុងត្រីមាសទី១ : ត្រូវបង់ពេញមួយឆ្នាំ
- ក្នុងត្រីមាសទី២ : ត្រូវបង់បីត្រីមាស
- ក្នុងត្រីមាសទី៣ : ត្រូវបង់ពីរត្រីមាស
- ក្នុងត្រីមាសទី៤ : ត្រូវបង់មួយត្រីមាស

## ជំពូកទី ៥
## អន្តរប្បញ្ញត្តិ

**ប្រការ ១៨.-**

ក្រុមហ៊ុន ដែលបានទទួលការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជារួចហើយ ត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ជាថ្មីស្របតាមខ្លឹមសារនៃប្រកាសនេះ មកធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលប្រកាសនេះ ចូលជាធរមាន។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**ប្រការ ១៩.-**

ក្រុមហ៊ុន ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវរងវិធានការរដ្ឋបាល ដូចជា ការព្រមាន ការណែនាំឲ្យកែតម្រូវកំហុស និងការដកហូតការទទួលស្គាល់ ជាដើម។



ℓ

**ប្រការ ២០.-**

ធនាគារជាតិនៃកម្ពុជា អាចដកហូតការទទួលស្គាល់ក្រុមហ៊ុន ក្នុងករណីក្រុមហ៊ុនៈ

១. ត្រូវបានដកហូតវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម វិញ្ញាបនបត្រចុះបញ្ជីជាសមាជិក វ.គ.ស.ក. និង/ឬ អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២. ប្រព្រឹត្តខុសធ្ងន់ធ្ងរពីគោលការណ៍គណនេយ្យ និង/ឬ សវនកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ឬច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀត និង/ឬ

៣. មិនបានអនុវត្តកាតព្វកិច្ចដូចមានចែងនៅក្នុងប្រកាសនេះ និងការតម្រូវផ្សេងទៀតពីធនាគារជាតិនៃកម្ពុជា។

ក្រុមហ៊ុនណាមួយដែលត្រូវបានដកហូតការទទួលស្គាល់ ត្រូវបញ្ចប់សកម្មភាពសវនកម្មរបស់ខ្លួនទាំងស្រុង គិតចាប់ពីថ្ងៃទទួលបានលិខិតដកហូតជាលាយលក្ខណ៍អក្សរ ពីធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជាអាចពិចារណាការដាក់ពាក្យស្នើសុំការទទួលស្គាល់ជាថ្មី បន្ទាប់ពីការទទួលស្គាល់ក្រុមហ៊ុនត្រូវបានដកហូត ក្នុងរយៈពេល ០៣ (បី) ឆ្នាំ។

**ប្រការ ២១.-**

ក្រុមហ៊ុន ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលពិន័យអន្តរការណ៍ជាទឹកប្រាក់ពី ១០.០០០.០០០ រៀល (ដប់លានរៀល) ទៅ ២០.០០០.០០០ រៀល (ម្ភៃលានរៀល)។

**ប្រការ ២២.-**

សវនដ្ឋានណា ដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ២៣.-**

សារាចរណែនាំលេខ ធ៧-០១០-០០២ ស.រ.ណ ស្តីពី ការជ្រើសរើសស្នងការគណនីឯករាជ្យ សម្រាប់ធ្វើសវនកម្មប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ និងរាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ២៤.-**

អគ្គលេខាធិការ អគ្គនាយកត្រួតពិនិត្យ អគ្គនាយកបច្ចេកទេស អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនសវនកម្មដែលត្រូវបានទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១៧

**ទេសាភិបាល**

**ជា.ចាន់តូ**

**<u>កន្លែងទទួល៖</u>**

- ដូចប្រការ ២៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**<u>ចម្លងជូន៖</u>**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**ឧបសម្ព័ន្ធ**

**Appendix**

# ពាក្យស្នើសុំ
# ការទទួលស្គាល់ក្រុមហ៊ុនសវនកម្ម
# ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

# Application for Accreditation of External Audit Firm for Banking and Financial Institutions

## ផ្នែកទី ១: ព័ត៌មានក្រុមហ៊ុនសវនកម្ម

## SECTION 1: Information of Audit Firm

១-ឈ្មោះបុគ្គលតំណាងក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំ:............................................

1- Name of Authorized Person for the Applying Firm:............................................

២-តួនាទីបុគ្គលតំណាងក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំ:............................................

2- Position of the Authorized Person for the Applying Firm:............................................

៣-ឈ្មោះក្រុមហ៊ុនសវនកម្ម:............................................

3- Name of Audit Firm:............................................

៤-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មលេខ:............................................

4- Company Registration N°: ............................................

៥-វិញ្ញាបនបត្រចុះបញ្ជីជាសមាជិករបស់ វ.គ.ស.ក លេខ:............................................

5- Certificate of Active Membership with KICPAA N°: ............................................

៦-អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី ក.ជ.គ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ:............................................

6- License for Audit Firm from the NAC of the MEF N°: ............................................

៧-អាសយដ្ឋានទីស្នាក់ការកណ្ដាលក្រុមហ៊ុន:............................................

7- Company Address: ............................................

៨-ទូរស័ព្ទ/ទូរសារ:............................................អ៊ីម៉ែល:............................................

8- Phone/Fax: ............................................E-mail:............................................

## ផ្នែកទី ២: ការផ្តល់សេវាកម្មរបស់ក្រុមហ៊ុនសវនកម្ម

**SECTION 2: Services of the Audit Firm**

៩- ការផ្តល់សេវាសវនកម្មនិងសេវាផ្សេងទៀតលើវិស័យធនាគារក្នុងរយៈពេល ០៣ ឆ្នាំចុងក្រោយ:

9- Audit and other services conducted for banking sector for the last 3 years

| កាលបរិច្ឆេទ<br>Date | ប្រភេទនៃការផ្តល់សេវាកម្ម<br>Type of Services | ឈ្មោះនិងប្រភេទស្ថាប័នទទួលសេវាកម្ម<br>Name and type of audited institutions |
|---|---|---|
| ................ | ................................................ | ........................................................ |
| ................ | ................................................ | ........................................................ |
| ................ | ................................................ | ........................................................ |
| ................ | ................................................ | ........................................................ |
| ................ | ................................................ | ........................................................ |

## ផ្នែកទី ៣: ឯកសារភ្ជាប់ជាមួយពាក្យស្នើសុំ

**SECTION 3: Enclosed Documents**

- ☐ ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម / Copy of Company Registration
- ☐ ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីជាសមាជិកសកម្ម វ.គ.ស.ក / Copy of Certificate of Active Membership with KICPAA
- ☐ ច្បាប់ចម្លងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្មពី ក.ជ.គ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ / Copy of License for Audit Firm from the NAC of the MEF
- ☐ ព័ត៌មានរបស់ក្រុមហ៊ុននិងផែនការអាជីវកម្ម / Company Profile and Business Plan
- ☐ បញ្ជីឈ្មោះដៃគូសវនកម្មដែលជាសមាជិកសកម្ម វ.គ.ស.ក / List of Audit Partners as Active Members with KICPAA
- ☐ ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីជាសមាជិកសកម្ម វ.គ.ស.ក របស់ដៃគូសវនកម្ម និងនាយក/អ្នកគ្រប់គ្រង / Copy of certificate of active membership with KICPAA of Audit Partners and Directors/Managers
- ☐ ប្រវត្តិរូបរបស់ដៃគូសវនកម្ម និងនាយក/អ្នកគ្រប់គ្រង ដែលមានបញ្ជាក់អំពីគុណវុឌ្ឍិ និងបទពិសោធន៍ការងារ / Curriculum Vitae of Audit Partners and Directors / Managers specifying qualifications and work experiences

- ☐ លិខិតថ្កោលទោសរបស់ដៃគូសវនកម្ម និងនាយក / អ្នកគ្រប់គ្រង / Criminal record of Audit Partners and Directors / Managers
- ☐ នីតិវិធីសវនកម្ម / Audit Manual
- ☐ របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យសម្រាប់រយៈពេល ០៣ ឆ្នាំ ចុងក្រោយ / Audited Financial Statements for the last 3 years
- ☐ បញ្ជីការងារសវនកម្មនិងសេវាផ្សេងទៀត ដែលបានធ្វើក្នុងរយៈពេល ០៣ ឆ្នាំចុងក្រោយ / List of audit and other services that have been performed for the last 3 years
- ☐ របាយការណ៍នៃការប្រែប្រួលជាសារវន្តរយៈពេល ០៣ ឆ្នាំ ចុងក្រោយ ដែលបានឬអាចប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលអាជីវកម្មរបស់ក្រុមហ៊ុនសវនកម្ម / Statement of material changes during the last 3 years that have affected or may affect the operation and business result of the audit firm
- ☐ ឯកសារភ្ជាប់ផ្សេងៗ (ប្រសិនបើមាន) / Other documents (If applicable)

**ផ្នែកទី ៤: សេចក្តីបញ្ជាក់**

**SECTION 4: Declarations**

ក្នុងនាមក្រុមហ៊ុនសវនកម្ម ខ្ញុំបាទ/នាងខ្ញុំ សូមធ្វើការបញ្ជាក់ថា៖

On behalf of the Audit Firm, I would like to declare that:

- ក្រុមហ៊ុននឹងទទួលខុសត្រូវចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីព័ត៌មានដែលបានផ្តល់ក្នុងពាក្យស្នើសុំនេះខុសពីការពិត។
- The Audit firm will take full responsibility under Cambodian Law in case there is any misleading information provided in this application.
- ក្រុមហ៊ុននឹងផ្តល់ព័ត៌មានជូនធនាគារជាតិនៃកម្ពុជា នូវរាល់ហេតុការណ៍ផ្លាស់ប្តូរណាមួយដែលកើតមានក្នុងអំឡុងពេលសិក្សាសំណុំលិខិត។
- The Audit firm will undertake to inform the NBC of any change material to this application which arises during the application being considered.

រាជធានីភ្នំពេញថ្ងៃទី_______/_______/_______

Phnom Penh, Date: ថ្ងៃ/dd ខែ/mm ឆ្នាំ/yyyy

ហត្ថលេខា និងត្រា

Signature and Seal